ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៦៧៧.សសរ

**សេចក្តីសម្រេច**

**ស្តីពី**

**ការបង្កើតគណៈកម្មការផ្តល់សាពស្របច្បាប់ដល់ពលករកម្ពុជាដែល**

**កំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញអនុក្រឹត្យលេខ១៦អនក្រ.បក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ៧៧អនក្រ.បក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញអនុក្រឹត្យលេខ២៨៣អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ



www.pheakdeylaw.com

- បានឃើញអនុក្រឹត្យលេខ១៨៤អនក្រ.បក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មចំណុះក្រសួងមហាផ្ទៃ
- បានឃើញសេចក្តីជូនដំណឹងលេខ១៦៥៩សជណ.អវ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្តីជូនដំណឹងលេខ១៥២៣សជណ.អវ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្តីជូនដំណឹងលេខ១២៤៥សជណ.អវ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## **សម្រេច**

**ប្រការ ១.-**

ត្រូវបានបង្កើតគណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម **អ៊ិត សំហេង** | រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ប្រធាន |
| ២- | ឯកឧត្តម **ព្រុំ សុខា** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធានទី១ |
| ៣- | ឯកឧត្តម **ពេជ សោភ័ន** | រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធាន |
| ៤- | ឯកឧត្តម **ឡុង វិសាលោ** | រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| ៥- | ឯកឧត្តម **គីមរ៉េត សំរេច** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៦- | ឯកឧត្តម **ហ៊ុន ម៉ាណែត** | មេបញ្ជាការបញ្ជាការដ្ឋានជាតិកម្លាំងពិសេសប្រឆាំងភេរវកម្ម | អនុប្រធាន |
| ៧- | លោកជំទាវ **អ៊ាត សោភា** | ឯកអគ្គរាជទូតកម្ពុជាប្រចាំព្រះរាជាណាចក្រថៃឡង់ដ៍ | សមាជិក |
| ៨- | ឯកឧត្តមនាយឧត្តមសេនីយ៍ **ម៉ៅ ច័ន្ទតារា** | អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ | សមាជិក |
| ៩- | ឯកឧត្តម **ហេង សួរ** | អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១០- | លោក **សួន សទ្ធាវុឌ្ឍី** | អគ្គនាយករងនៃអគ្គនាយកដ្ឋានការងារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១១- | លោកឧត្តមសេនីយ៍ត្រី **អ៊ុក គឹមអរធិការ** | អនុប្រធាននាយកដ្ឋានលិខិតឆ្លងដែន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម | សមាជិក |
| ១២- | លោក **សេដ្ឋា ខន្ធ្យនា** | ជំនួយការខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន | សមាជិក |
| ១៣- | លោក **ជៀម ឡាម៉ានីន** | ទីប្រឹក្សាទទួលបន្ទុកការងារពលករនៃស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំព្រះរាជាណាចក្រថៃឡង់ដ៍ | សមាជិក |
| ១៤- | លោក **ហែម ម៉ុននី** | ប្រធាននាយកដ្ឋានមុខរបរ និងហត្ថពលកម្ម ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |



www.pheakdeylaw.com

១៥- លោក **គឹម ចំរើន** ទីប្រឹក្សាក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក
១៦- លោក **ឃឹម សុសំរេច** ប្រធានលេខាធិការដ្ឋានអគ្គនាយកដ្ឋានការងារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក។

**ប្រការ ២.-**

គណៈកម្មការនេះ មានតួនាទី និងភារកិច្ចដូចតទៅ៖

- សម្របសម្រួលជាមួយអង្គភាព ស្ថាប័នជាតិ និងភាគីថៃដើម្បីអនុវត្តនូវស្មារតី ដែលបានព្រមព្រៀងគ្នារវាងក្រុមការងារបច្ចេកទេសនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងការងារនៃព្រះរាជាណាចក្រថៃឡង់ដ៍
- បង្កើត និងចាត់តាំងលេខាធិការដ្ឋានអចិន្ត្រៃយ៍ប្រចាំស្ថានឯកអគ្គរាជទូតកម្ពុជានៅទីក្រុងបាងកក ដែលមានតំណាងក្រសួងមហាផ្ទៃជាប្រធាន និងតំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាអនុប្រធានទី១ ដើម្បីសម្របសម្រួលការងាររបស់ក្រុមការងារអន្តរក្រសួងចល័ត និងក្រុមការងារបោះពុម្ពលិខិតឆ្លងដែន
- ចាត់តាំងក្រុមការងារអន្តរក្រសួងចល័តដែលមានមន្ត្រីអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម និងមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ទៅផ្តល់ឯកសារចាំបាច់នានាដូចជា ប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស លិខិតឆ្លងដែន ប័ណ្ណអនុញ្ញាតស្នាក់នៅ និងប័ណ្ណអនុញ្ញាតការងាររបស់ថៃ ដើម្បីផ្តល់ភាពស្របច្បាប់ជូនពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ហើយបានចុះឈ្មោះក្នុងបញ្ជីជំរឿនរបស់ភាគីថៃ
- កំណត់នូវរបៀបរបប នីតិវិធីការងារ និងផែនការសកម្មភាពរបស់ក្រុមការងារអន្តរក្រសួងចល័ត
- កំណត់យន្តការ និងចិរវេលាច្បាស់លាស់ក្នុងការផ្តល់ភាពស្របច្បាប់ដល់ពលករ
- គ្រប់គ្រងចំណូលសេវាទ្រទ្រង់ឱ្យមានតម្លាភាព និងសមភាព
- កំណត់នូវគោលការណ៍ឧបត្ថម្ភដល់មន្ត្រីនៃក្រុមការងារចល័តអន្តរក្រសួង និងសមាជិកនៃគណៈកម្មការ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សម្របសម្រួលនីតិវិធីការទូតជាមួយភាគីថៃ ក្នុងការរៀបចំទីកន្លែងឱ្យក្រសួងមហាផ្ទៃ បោះពុម្ពលិខិតឆ្លងដែន នៅក្នុងស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំទីក្រុងបាងកក ជូនពលករកម្ពុជាដែលមិនទាន់មានឯកសារគ្រប់គ្រាន់ ហើយកំពុងធ្វើការនៅប្រទេសថៃ
- និងការងារផ្សេងទៀតតាមការចាំបាច់។

**ប្រការ ៣.-**

ប្រធានគណៈកម្មការមានសិទ្ធិសម្រេចចាត់តាំងលេខាធិការដ្ឋានអចិន្ត្រៃយ៍ និងក្រុមការងារអន្តរក្រសួងចល័ត បន្ទាប់ពីបានពិគ្រោះ យោបល់ជាមួយស្ថាប័នពាក់ព័ន្ធពីបញ្ហាដែលពាក់ព័ន្ធតាមសមត្ថកិច្ច។

**ប្រការ ៤.-**

គណៈកម្មការនេះ មានសិទ្ធិប្រើប្រាស់ត្រាក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**ប្រការ ៥.-**

គណៈកម្មការនេះ មានប្រភពធនធានផ្គត់ផ្គង់ដោយថវិកាថ្លៃសេវាដែលប្រមូលបាន និងមានសិទ្ធិទទួលគ្រប់គ្រង និងចាត់ចែងមូលនិធិដែលទទួលបានពីប្រភពហិរញ្ញប្បទានសហប្រតិបត្តិការជាមួយដៃគូជាតិ អន្តរជាតិ និងពីប្រភពផ្សេងៗទៀតសម្រាប់បំពេញការងាររបស់ខ្លួន។



www.pheakdeylaw.com

**ប្រការ ៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ ៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រធានអង្គភាពពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ២០១៤*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



www.pheakdeylaw.com